ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកំពង់ចាម**

**សាលក្រមព្រហ្មទណ្ឌ**
លេខ២៣៣ ( គ )
ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០២២
-សំណុំរឿងព្រហ្មទណ្ឌលេខ៥៤១
ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៧
-សំណុំរឿងស៊ើបសួរលេខ៣៥៥
ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៨
-សំណុំរឿងជំនុំជំរះលេខ១១៣៥
ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២០

**តាងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្តកំពង់ចាម**

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ វេលាម៉ោង៨នាទីព្រឹក នៅសាលសវនាការទី១ដោយមានសមាសភាព:

**ចៅក្រមជំនុំជម្រះ**

-លោក [redacted] ចៅក្រមជំនុំជម្រះសាលាដំបូងខេត្តកំពង់ចាម ។

**តំណាងអយ្យការ**

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកំពង់ចាម ។

**ក្រឡាបញ្ជីសវនាការ**

-លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ចាម ។

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ៥៤១ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៧ ដែលមានជនជាប់ចោទ:

១-ឈ្មោះ[redacted] **ឌីណា** ហៅ **ស្រីទូច** ភេទស្រី អាយុ២៤ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើត និង ទីលំនៅបច្ចុប្បន្ន[redacted] ខេត្តកំពង់ចាម មុខរបរកសិករ ឪពុកឈ្មោះ[redacted] **វឿន** (រ) ម្តាយឈ្មោះ[redacted] **ធារី** (រ) ប្តីឈ្មោះ[redacted] **អ៊ីវម៉ិញ** មានកូន០២នាក់ ជានីតិជន ។ (ក្រៅឃុំ) ។

២-ឈ្មោះ[redacted] **អ៊ីវម៉ិញ** ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្នភូមិ[redacted] ខេត្តកំពង់ចាម មុខរបរកសិករ ឪពុកឈ្មោះ[redacted] ប្រា (រ), ម្តាយឈ្មោះ[redacted] សុភាព (រ) ប្រពន្ធឈ្មោះ[redacted] **ឌីណា** មានកូន ០២នាក់ ជានីតិជន ។ (ក្រៅឃុំ) ។

ជាប់ចោទពីបទ: **ធ្វើឱ្យខូចខាតដោយចេតនា** ប្រព្រឹត្តនៅភូមិស្រែក ឃុំស្រែក ស្រុកកំពង់សៀម ខេត្តកំពង់ចាម កាលពីថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៧ តាមមាត្រា៤១០នៃក្រមព្រហ្មទណ្ឌ ។

មានមេធាវីលោក[redacted] ។

៣-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] **គីមអ៊ី** ភេទប្រុស អាយុ២៩ឆ្នាំ ជាតិខ្មែរ មុខរបរជាងឡាន ទីកន្លែងកំណើតភូ[redacted]ខេត្តកំពង់ចាម ទីលំនៅសព្វថ្ងៃភូមិព្រៃករលួស ឃុំព្រៃកបាក់ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ឪពុកឈ្មោះ[redacted] ឈុនលី (រ) ម្តាយឈ្មោះ[redacted] **ស៊ាងលីម** (រ) ប្រពន្ធឈ្មោះ[redacted]**ដាលីន** មានកូន១នាក់ ។

មានមេធាវីលោក[redacted] ។



Scanned with CamScanner

៤-សាក្សីឈ្មោះ [redacted] សារឿន ភេទប្រុស អាយុ៥៨ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិព្រៃករលួស ឃុំព្រែកបាក់ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ។

៥-សាក្សីឈ្មោះ [redacted] ឆារី ភេទស្រី អាយុ៥៥ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិព្រៃករលួស ឃុំព្រែកបាក់ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ។

**<u>អង្គហេតុនៃរឿងមានដូចតទៅ</u>**

កាលពីថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៧ នៅចំណុចភូមិស្រែក ឃុំស្រែក ស្រុកកំពង់សៀម ខេត្តកំពង់ចាម មានជនជាប់ចោទឈ្មោះ [redacted] **ឌីណា ហៅ ស្រីទូច** រួមទាំងប្តីឈ្មោះ [redacted] **អ៊ីវម៉ិញ** បាននាំគ្នាទៅកាប់បំផ្លាញដំណាំស្វាយចន្ទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **គឹមអ៊ី** ចោលអស់ចំនួន៤៥ដើម ហើយយកបង្គោលព្រំទៅបោះរំលោភចូលដីរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **គឹមអ៊ី** តាមទទឹងព្រំដីអស់០៦ម៉ែត្រ បណ្តោយអស់ប្រវែង៥០ម៉ែត្រ ។

-**បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ៦៥២ព.ស ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ចាម ។

-**បានឃើញ** ដីកាដំណោះស្រាយលេខ២០២៣ ព.ស ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពង់ចាម ។

-**បានឃើញ** ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ១៤២២ ចត ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២០ របស់អនុប្រធានសាលាដំបូងខេត្តកំពង់ចាម ។

-**បានឃើញ** ដីកាចាត់តាំងតំណាងអយ្យការជំនុំជម្រះលេខ១៣៧ អក.ពស/២១ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២១ របស់ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តកំពង់ចាម ។

**នាពេលសវនាការ**

១-ជនជាប់ចោទឈ្មោះ [redacted] **ឌីណា ហៅ ស្រីទូច** បានឆ្លើយសារភាពថាៈ ខ្លួនបានកាប់ដើមស្វាយចន្ទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **គឹមអ៊ី** មែន តែនៅលើដីរបស់ឈ្មោះ [redacted] **សារឿន** ជាឪពុករបស់ខ្លួនទេ កាប់ហើយដាំថ្មីវិញ ។

២-ជនជាប់ចោទឈ្មោះ [redacted] **អ៊ីវម៉ិញ** បានឆ្លើយថាៈ ខ្លួនឯកភាពតាមចម្លើយរបស់ឈ្មោះ [redacted] **ឌីណា ហៅ ស្រីទូច** ជាប្រពន្ធរបស់ខ្លួន ។

៣-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **គឹមអ៊ី** (អវត្តមាន) ក្រឡាបញ្ជីបានអានកំណត់ហេតុសួរយកចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **គឹមអ៊ី** ។

៤-សាក្សីឈ្មោះ [redacted] **សារឿន** បានឆ្លើយថាៈ កូនរបស់ខ្លួនកាប់ស្វាយចន្ទីនៅលើដីរបស់ខ្លួនទេ មិនបានកាប់ស្វាយចន្ទីលើដីរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **គឹមអ៊ី** នោះទេ ។ ពេលធ្វើប្លង់ចុះមកវាស់វែងបានមួយដង តែក្រោយមក២ឆ្នាំទៀតមកវាស់វែងម្តងទៀតនៅពេលមានរឿងនេះតែម្តង ។

៥-សាក្សីឈ្មោះ [redacted] **ឆារី** បានឆ្លើយថាៈ ដីនេះជាដីរបស់ខ្លួនកាប់ស្វាយចន្ទីរបស់ខ្លួនមែន តែមិនបានដក ឬកាប់ស្វាយចន្ទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **គឹមអ៊ី** នោះទេ ។ សុរិយោដីបានចុះមកវាស់វែងបានមួយដង ពេលចេញប្លង់រឹង តែក្រោយនេះមិនបានចុះមកវាស់វែងទៀតទេ ។



Scanned with CamScanner

## សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-តម្កល់ការចោទប្រកាន់របស់ខ្លួនទុកនៅដដែល និង សុំឲ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមមាត្រា៤១០នៃក្រមព្រហ្មទណ្ឌ ។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារដើមបណ្តឹងរដ្ឋប្បវេណី

-លោក [redacted] ជាមេធាវីការពារដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **គឹមអ៊ី** បានធ្វើសេចក្តីសន្និដ្ឋានថាៈ ជនជាប់ចោទឈ្មោះ [redacted] **ឌីណា ហៅ ស្រីទូច** និង ឈ្មោះ [redacted] **ស៊ីវម៉ិញ** ទទួលស្គាល់បានកាប់ខ្លះ និង មិនបានកាប់ខ្លះព្រមព្រៀងទទួលយកការសងដើមស្វាយចន្ទីមែន តែមិនបានសងក៏ប្តឹងមកតុលាការតែម្តង ។ សុំតុលាការសម្រេចតាមពាក្យបណ្តឹង និង ផ្តន្ទាទោសជនល្មើសតាមច្បាប់ ។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-លោក [redacted] ជាមេធាវីការពារជនជាប់ចោទឈ្មោះ [redacted] **ឌីណា ហៅ ស្រីទូច** និង ឈ្មោះ [redacted] **ស៊ីវម៉ិញ** បានធ្វើសេចក្តីសន្និដ្ឋានថាៈ ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **គឹមអ៊ី** នៅព្រៃទទឹង ឪពុករបស់គាត់ជាអ្នកដាំ ។ កូនក្តីខ្លួនទៅថៃដំណាំរបស់គាត់ មិនបានដឹងដំណាំរបស់គេទេ បែរជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **គឹមអ៊ី** ប្តឹងពីកូនក្តីខ្លួនទៅវិញ ។ ដីនេះមានប័ណ្ណកម្មសិទ្ធិរបស់ឪពុកកូនក្តីរបស់ខ្លួន មេប៉ុស្តិ៍ និង មេភូមិ បញ្ជាក់របាយការណ៍ដូចគ្នាដែរ ។ មានកំណត់ហេតុតទល់រវាងជនជាប់ចោទ និង ដើមបណ្តឹងរដ្ឋប្បវេណី ឃើញថាបើវាស់ទៅឃើញចូលដីនេះមែនសុំសងពាក់កណ្តាលភាគីសុំបញ្ចប់រឿង ។ សំណូមពរសុំឲ្យតុលាការលើកលែងចោទប្រកាន់កូនក្តីរបស់ខ្លួន ។

## សំដីចុងក្រោយរបស់ជនជាប់ចោទ

-សុំឲ្យតុលាការលើកលែងទោសដល់ពួកខ្លួនផង ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទទាំង២នាក់ ។

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **គឹមអ៊ី** ។

-ក្រោយពីបានស្តាប់ចម្លើយរបស់សាក្សីទាំង២នាក់ ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទទាំង២នាក់ ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **គឹមអ៊ី** ។

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទទាំង២នាក់ ។

-ក្រោយពីបានពិនិត្យលើឯកសារភស្តុតាងនានាត្រឹមត្រូវហើយ ។

-ក្រោយពីបានពិនិត្យ និង ពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។

## <u>យល់ឃើញថា</u>

១-តាមដីកាបញ្ជូនសំណុំរឿងមកជំនុំជម្រះបញ្ជូនជនជាប់ចោទឈ្មោះ [redacted] **ឌីណា ហៅ ស្រីទូច** ភេទស្រី អាយុ២៤ឆ្នាំ ជាតិខ្មែរ និង ឈ្មោះ [redacted] **អ៊ីវម៉ិញ** ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ ដាក់ក្រោមការត្រួតពិនិត្យពីបទៈ **ធ្វើឱ្យខូចខាតដោយចេតនា** ប្រព្រឹត្តនៅភូមិស្រែក ឃុំស្រែក ស្រុកកំពង់សៀម ខេត្តកំពង់ចាម កាលពីថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៧ តាមមាត្រា៤១០នៃក្រមព្រហ្មទណ្ឌ ។



Scanned with CamScanner

២-ជនជាប់ចោទឈ្មោះ[redacted] ឌីណា ហៅ ស្រីទូច បានឆ្លើយសារភាពថា: ខ្លួនបានកាប់ដើមស្វាយចន្ទីរបស់មែនដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] គីមអ៊ី តែនៅលើដីរបស់ឈ្មោះ[redacted] សារឿន ជាឪពុករបស់ខ្លួន កាប់ហើយដាំថ្មីវិញ ។

៣-ជនជាប់ចោទឈ្មោះ[redacted] អ៊ីវម៉ិញ បានឆ្លើយថា: ខ្លួនឯកភាពតាមចម្លើយរបស់ឈ្មោះ[redacted] ឌីណា ហៅ ស្រីទូច ជាប្រពន្ធរបស់ខ្លួន ។

៤-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] គីមអ៊ី (អវត្តមាន) ក្រឡាបញ្ជីបានអានកំណត់ហេតុសួរយកចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] គីមអ៊ី បានឆ្លើយថា: ក្នុងរឿងនេះខ្លួនទាមទារសំណងចំនួន២០.០០០.០០០រៀល (ម្ភៃលានរៀល) និង សុំឲ្យតុលាការមេត្តារកយុត្តិធម៌ដល់រូបខ្លួនផង ។

៥-សាក្សីឈ្មោះ[redacted] សារឿន បានឆ្លើយថា: កូនរបស់ខ្លួនកាប់ស្វាយចន្ទីនៅលើដីរបស់ខ្លួនទេ មិនបានកាប់ស្វាយចន្ទីលើដីរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] គីមអ៊ី នោះទេ ។

៦-សាក្សីឈ្មោះ[redacted] ឆារី បានឆ្លើយថា: ដីនេះជាដីរបស់ខ្លួនកាប់ស្វាយចន្ទីរបស់ខ្លួនមែន តែមិនបានដក ឬកាប់ស្វាយចន្ទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] គីមអ៊ី នោះទេ ។

៧-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ: តម្កល់ការចោទប្រកាន់របស់ខ្លួនទុកនៅដដែល ។

៨-លោក [redacted] ជាមេធាវីការពារដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] គីមអ៊ី បានធ្វើសេចក្តីសន្និដ្ឋានថា: តុលាការសម្រេចតាមពាក្យបណ្តឹង និង ផ្តន្ទាទោសជនល្មើសតាមច្បាប់ ។

៩-លោក [redacted] ជាមេធាវីការពារជនជាប់ចោទឈ្មោះ[redacted] ឌីណា ហៅ ស្រីទូច និង ឈ្មោះ [redacted] ស៊ីវម៉ិញ បានធ្វើសេចក្តីសន្និដ្ឋានថា: សុំឲ្យតុលាការលើកលែងចោទប្រកាន់ ។

១០-តាមគំនូសបង្ហាញទ្រង់ទ្រាយក្បាលដីទំនាស់ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០២២ របស់ប្រធានការិយាល័យសុរិយោដីស្រុកកំពង់សៀម បានបញ្ជាក់ថា ដីទំនាស់ពិតជាចូលទៅក្នុងដីរបស់ឈ្មោះ[redacted] គីមអ៊ី ពិតប្រាកដមែន ។

១១-តាមកំណតហេតុតទល់ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួររវាងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] គីមអ៊ី និង ជនជាប់ចោទឈ្មោះ[redacted] ឌីណា ហៅ ស្រីទូច និង ឈ្មោះ[redacted] អ៊ីវម៉ិញ បានឆ្លើយបញ្ជាក់ថា ពួកខ្លួនស្នើសុំឲ្យមន្ត្រីជំនាញចុះវាស់ទីតាំងដីទំនាស់នេះ ប្រសិនបើព្រំដីទំនាស់ស្ថិតត្រង់នៅកន្លែងណានោះពួកខ្លួនយល់ព្រមតាមការវាស់នេះ បើដំណាំស្ថិតនៅលើដីរបស់ជនត្រូវចោទឈ្មោះ[redacted] ឌីណា ហៅ ស្រីទូច និង ឈ្មោះ[redacted] អ៊ីវម៉ិញ ខ្ញុំបាទឈ្មោះ[redacted] គីមអ៊ី យល់ព្រមបញ្ចប់រឿងមិនទាមទារសំណងទេ តែប្រសិនបើវាស់ទៅឃើញចូលដីរបស់ខ្លួនជនជាប់ចោទឈ្មោះ[redacted] ឌីណា ហៅ ស្រីទូច និង ឈ្មោះ[redacted] អ៊ីវម៉ិញ យល់ព្រមសងដើមស្វាយចន្ទីរបស់ខ្លួនក្នុង១ដើមចំនួន ៤០,០០០រៀល ក្នុងនោះមានចំនួន៤៩ដើម ។

ដូច្នេះគប្បីតុលាការសម្រេចការទាមទារពីសំណងតាមការព្រមព្រៀងរបស់គូភាគីខាងលើនេះ ។

១២-មានធាតុផ្សំ និង ភស្តុតាងគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ[redacted] ឌីណា ហៅ ស្រីទូច ភេទស្រី អាយុ២៤ឆ្នាំ និង ឈ្មោះ[redacted] អ៊ីវម៉ិញ ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ ដាក់ក្រោមការត្រួតពិនិត្យពីបទ: **ធ្វើឱ្យខូចខាតដោយចេតនា** ប្រព្រឹត្តនៅភូមិស្រែក ឃុំស្រែក ស្រុកកំពង់សៀម ខេត្តកំពង់ចាម កាលពីថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៧ តាមមាត្រា៤១០នៃក្រមព្រហ្មទណ្ឌ ។



Scanned with CamScanner

១៣-បទល្មើសនេះ ជាបទមជ្ឈិមការផ្តន្ទាទោសតិចជាងឬស្មើ៥ឆ្នាំ ។ ដូច្នេះគប្បីតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] ឌីណា ហៅ ស្រីទូច និង ឈ្មោះ [redacted] អ៊ីវម៉ិញ ព្យួរធម្មតាតាមមាត្រា១០៤ និង មាត្រាបន្តបន្ទាប់នៃក្រមព្រហ្មទណ្ឌ ។

**ហេតុដូច្នេះសម្រេច**

១-ផ្តន្ទាទោសលើជនជាប់ចោទៈ

-ឈ្មោះ [redacted] ឌីណា ហៅ ស្រីទូច ភេទស្រី អាយុ២៤ឆ្នាំ ជាតិខ្មែរ.....។

-ឈ្មោះ [redacted] អ៊ីវម៉ិញ ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ....។

សម្រេចដាក់ពន្ធនាគារម្នាក់ៗកំណត់រយៈពេលចំនួន**០១ឆ្នាំ (មួយឆ្នាំ)** តែទោសនេះព្យួរធម្មតាពីបទៈ**ធ្វើឱ្យខូចខាតដោយចេតនា** ប្រព្រឹត្តនៅភូមិស្រែក ឃុំស្រែក ស្រុកកំពង់សៀម ខេត្តកំពង់ចាម កាលពីថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៧ តាមមាត្រា៤១០នៃក្រមព្រហ្មទណ្ឌ ។

២-បង្គាប់ឲ្យជាប់ចោទឈ្មោះ [redacted] ឌីណា ហៅ ស្រីទូច និង ឈ្មោះ [redacted] អ៊ីវម៉ិញ រួមគ្នាសងថ្លៃខូចខាតដើមស្វាយចន្ទីចំនួន១.៩៦០.០០០រៀល ទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] គឹមអ៊ី គិតពីថ្ងៃសាលក្រមចូលជាស្ថាពរតទៅ ។

៣-សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ និង ប្រកាសជាសាធារណៈនៅថ្ងៃទី១១ ខែមេសា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ឌីណា ហៅ ស្រីទូច ,ឈ្មោះ [redacted] អ៊ីវម៉ិញ និង កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] គឹមអ៊ី បើកផ្លូវប្តឹងទាស់ និង ប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

| **ក្រឡាបញ្ជី** | **ចៅក្រមជំនុំជម្រះ** |
|---|---|
| ហត្ថលេខា និង [redacted] | ហត្ថលេខា និង ត្រា [redacted] |

(បានចម្លងត្រឹមត្រូវតាមច្បាប់ដើម)

ថ្ងៃចន្ទ ២រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៥

កំពង់ចាម ,ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

**បានឃើញ**

**ចៅក្រមជំនុំជម្រះ**

[redacted]

[redacted]